**សហភាពអឺរ៉ុប**

**ប្រតិភូប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

# កិច្ចប្រជុំកំពូលធុរៈកិច្ចលើកទី ២ រវាងអាស៊ាន និងសហភាពអឺរ៉ុប នឹងប្រារព្ធធ្វើឡើងនៅ រាជធានីភ្នំពេញ

*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២* - បន្ទាប់ពីជោគជ័យនៃកិច្ចប្រជុំកំពូលធុរៈកិច្ចលើកទី ១ រវាងអាស៊ាននិងសហភាពអឺរ៉ុបកាលពីខែ ឧសភា ឆ្នាំមុន នៅទីក្រុងហ្សាកាតានៃប្រទេសឥណ្ឌូនេស៊ី កិច្ចប្រជុំកំពូលធុរៈកិច្ចលើកទី ២ រវាងអាស៊ាននិងសហភាពអឺរ៉ុបឆ្នាំនេះ នឹងត្រូវប្រារព្ធធ្វើឡើង នៅរាជធានីភ្នំពេញ នាថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១២ ខាងមុខនេះ។

កិច្ចប្រជុំកំពូលធុរៈកិច្ចលើកទី ២ រវាងអាស៊ាន និងសហភាពអឺរ៉ុបនេះ នឹងនាំអោយមានការជួបជុំគ្នារវាងសហគ្រិនវិនិយោគិនឯកជន និងអ្នករៀបចំគោលនយោបាយសាធារណៈ មកពីសហភាពអឺរ៉ុបនិងអាស៊ាន ដើម្បីដោះស្រាយបញ្ហា ចម្បងៗមួយចំនួនដែលទាក់ទងនឹងទំនាក់ទំនងពាណិជ្ជកម្មរវាងសហភាពអឺរ៉ុបនិងអាស៊ាន ទន្ទឹមនឹងនេះ កំណត់រកកាលានុវត្តភាពផ្នែកពាណិជ្ជកម្ម និងវិនិយោគថ្មីៗសម្រាប់ភាគីទាំងសងខាងគឺអាស៊ាននិងសហភាពអឺរ៉ុប ។

កិច្ចប្រជុំកំពូលនេះ នឹងផ្តល់ដល់អ្នកចូលរួមមកពីវិស័យឯកជននៃសហភាពអឺរ៉ុបនិងអាស៊ាន នូវឱកាសដ៏កម្រមួយដើម្បីផ្លាស់ប្តូរបទពិសោធន៏ និងលើកយកមកពិភាក្សាដោយផ្ទាល់អំពីបញ្ហារបស់ពួកគេលើទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគរវាង អាស៊ាននិងសហភាពអឺរ៉ុប ជាមួយនឹងរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន（AEM）និងឯកឧត្តម Karel De Gucht ស្នងការនៃគណៈកម្មការសហភាពអឺរ៉ុបទទួលបន្ទុកផ្នែកពាណិច្ចកម្ម។

ឯកឧត្តមឯកអគ្គរដ្ឋទូត Jean-François Cautain ប្រធានប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា បានមានប្រសាសន៏ថា *"ឆ្នាំ ២០១២ គឺជាខួបលើកទី ៣៥ នៃទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការរវាង ការផ្តួចផ្តើមធ្វើសមាហរ័ណកម្មតំបន់ដ៏ធំចំនួនពីរនៅក្នុងពិភពលោក ពោលគឺ សហភាពអឺរ៉ុប និង អាស៊ាន។ សហភាពអឺរ៉ុប និង អាស៊ាន គឺជាដៃគូដ៏មានសារៈសំខាន់លើវិស័យពាណិជ្ជកម្ម។ នៅក្រៅ ទ្វីបអឺរ៉ុប អាស៊ាន ជារួម គឺជាដៃគូពាណិជ្ជកម្មធំបំផុតទី ៣ របស់សហភាពអឺរ៉ុប បន្ទាប់ពីសហរដ្ឋអាមេរិក និង ចិន ដោយមានតម្លៃពាណិជ្ជកម្ម លើផ្នែកផលិតផលនិងសេវាកម្មគិតជាទឹកប្រាក់ច្រើនជាង ១៧៥ ពាន់លានអឺរ៉ូ នៅឆ្នាំ ២០១០។ សហភាពអឺរ៉ុប គឺជាដៃគូនាំចេញធំបំផុតរបស់អាស៊ាន ដោយមានតម្លៃនាំចេញជាង ៩០ ពាន់លានអឺរ៉ូ នៅឆ្នាំ ២០១១។ សហភាពអឺរ៉ុប និង អាស៊ាន មានសារៈសំខាន់បំពេញអោយគ្នាទៅវិញទៅមកខាងផ្នែកសេដ្ឋកិច្ច ហេតុនេះហើយទើបខ្ញុំអាចរំពឹងទុកថា កិច្ចប្រជុំកំពូលដែលនឹងធ្វើឡើងនៅឆ្នាំនេះ ក្នុងរាជធានីរបស់អាស៊ាននោះគឺ រាជធានីភ្នំពេញ នឹងជាព្រឹត្តិការណ៍ធុរៈកិច្ចមួយប្រកបដោយភាពរស់រវើក និងប្រកបដោយផ្លែផ្កា"* ។

No 100A – Preah Norodom Boulevard – Khan Daun Penh –12207 Phnom Penh – Cambodia
Tel: 855-23-216 996 / 211 102 / 220 611 / 220 612 – Fax: 855-23-216 997 – E-mail: Delegation-Cambodia@eeas.europa.eu
Website: http://eeas.europa.eu/delegations/cambodia

កិច្ចប្រជុំកំពូលធុរៈកិច្ចលើកទី ២ រវាងអាស៊ាន និង សហភាពអឺរ៉ុបនេះ ត្រូវបានរៀបចំធ្វើឡើង ដោយក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ប្រតិភូសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា សភាពាណិជ្ជកម្មអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា និងសភាពាណិជ្ជកម្មជា។ ថ្នាក់ដឹកនាំពាណិជ្ជកម្មអន្តរជាតិប្រមាណ ៣០០ នាក់ ត្រូវបានរំពឹងថា នឹងមានវត្តមាននៅក្នុងកិច្ចប្រជុំរយៈពេលមួយថ្ងៃនេះ ដែលក្នុងនោះរួមមានកិច្ចពិភាក្សា និងកិច្ចប្រជុំបិទទ្វារ ដោយផ្តោតលើការរកវិធីកែលម្អដំណើរការទំនាក់ទំនងពាណិជ្ជកម្ម នៅក្នុងវិស័យដែលពាក់ព័ន្ធច្រើនបំផុតលើផ្នែកពាណិជ្ជកម្ម និង វិនិយោគ។ កិច្ចពិភាក្សាតាមវិស័យ នឹងត្រូវរៀបចំឡើង បន្ទាប់ពីកិច្ចពិភាក្សាជាចំហ លើភាពជាដៃគូធុរៈកិច្ចរវាងសហភាពអឺរ៉ុប និងអាស៊ាន ដោយផ្អែកទៅលើពាណិជ្ជកម្ម និង វិនិយោគប្រកបដោយនិរន្តរភាព ក្នុងនោះមាន ការពិភាក្សាអំពីទិដ្ឋភាពនៃការទទួលខុសត្រូវផ្នែកសង្គមរបស់សារជីវកម្ម (CSR) និងបទពិសោធន៏ល្អៗផងដែរ ។ វិស័យនានាដែលត្រូវលើកយកមកពិភាក្សាមានដូចជា ១- កសិ-ពាណិជ្ជកម្ម (ការកែច្នៃ ម្ហូបអាហារ ការផលិតភេសជ្ជៈ) ២- ហេដ្ឋារចនាសម្ព័ន្ធ/ទំនាក់ទំនង (ថាមពល ផ្នែកផ្គត់ផ្គង់ភស្តុភា ការដោះស្រាយចំពោះឧបសគ្គទាក់ទងនឹងលទ្ធភាពប្រើប្រាស់ទីផ្សារ) ៣-កម្មន្តសាល (ផ្នែកផលិតយានយន្ត និងឱសថ) និង ៤- សេវាកម្ម (ផ្នែកហិរញ្ញវត្ថុ ធានារ៉ាប់រង បច្ចេកវិទ្យាព័ត៌មាន និងទូរគមន៏ (ICT)) ។

ឯកឧត្តម Jean-François Cautain បានមានប្រសាសន៏បន្ថែមទៀតថា *"ខ្ញុំសង្ឃឹមថា កិច្ចប្រជុំកំពូលធុរកិច្ចលើកទី ២ រវាងអាស៊ាន និងសហភាពអឺរ៉ុបឆ្នាំនេះ នឹងរួមចំណែកយ៉ាងសំខាន់ដល់ការលើកកម្ពស់លំហូរពាណិជ្ជកម្ម និង វិនិយោគរវាងតំបន់ទាំងពីរ ដោយ ក្នុងនោះ ត្រូវស្វែងរកវិធីកាត់បន្ថយអោយបានច្រើនបំផុតនូវឧបសគ្គ និងបញ្ហាពាក់ព័ន្ធនឹងទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគរវាងបណ្តាប្រទេសអាស៊ាន និងផ្សាររួមរបស់សហភាពអឺរ៉ុប ។ ខ្ញុំរង់ចាំដោយរីករាយចង់ឃើញការពិភាក្សាយ៉ាងផុលផុស ដោយសហគមន៏អ្នកធុរៈកិច្ច និងការផ្តល់អនុសាសន៏ល្អៗសំរាប់ធ្វើអោយបរិយាកាសពាណិជ្ជកម្មបានប្រសើរឡើង ដើម្បីដាក់ជូនរដ្ឋមន្ត្រីពាណិជ្ជកម្ម និងសេដ្ឋកិច្ចអាស៊ានចំនួន ១០ រូប និងស្នងការនៃគណៈកម្មការនៃសហភាពអឺរ៉ុបទទួលបន្ទុកពាណិជ្ជកម្ម" ។*

ឯកឧត្តម ឯកអគ្គរដ្ឋទូត Jean-François Cautain បានមានប្រសាសន៏ ទាក់ទងនឹងកិច្ចពិភាក្សាស្តីពីការទទួលខុសត្រូវផ្នែកសង្គមរបស់សារជីវកម្ម ថា *"ទាំងសហភាពអឺរ៉ុប និងអាស៊ាន មានគោលការណ៏ និងទិសដៅសំខាន់របស់ខ្លួនក្នុងការជំរុញកំណើនសេដ្ឋកិច្ចអោយមាននិរន្តរភាព ។ វាមានការផ្សារភ្ជាប់គ្នាដ៏ខ្លាំងក្លា រវាងការអភិវឌ្ឍពាណិជ្ជកម្មប្រកបដោយនិរន្តរភាព និង ការទទួលខុសត្រូវផ្នែកសង្គមរបស់សារជីវកម្ម ។ អ្នកខ្លះ អះអាងថា ការឆ្លើយតបទៅនឹងវិធីអនុវត្តន៏ត្រឹមត្រូវទាក់ទងនឹង ការទទួលខុសត្រូវផ្នែកសង្គមរបស់សារជីវកម្ម មិនត្រឹមតែមានលក្ខណៈចាំបាច់បំផុតសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចអោយមាននិរន្តរភាពរយៈពេលវែងប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងមានឥទ្ធិពលវិជ្ជមានបំផុតលើពាណិជ្ជកម្មផងដែរ ។ កិច្ចប្រជុំកំពូលធុរៈកិច្ចលើកទី ២ រវាងអាស៊ាន និងសហភាពអឺរ៉ុបនេះ នឹងក្លាយជាវេទិកាដ៏ល្អមួយសម្រាប់ផ្សព្វផ្សាយ និងផ្លាស់ប្តូរបទពិសោធន៏លើការអនុវត្តន៏ដ៏ល្អជាច្រើនទាក់ទងនឹងការទទួលខុសត្រូវសង្គមរបស់សារជីវកម្ម រវាងស្ថាប័នពាណិជ្ជកម្ម និងវិនិយោគ ដ៏ធំទាំងពីរ គឺសហភាពអឺរ៉ុប និងអាស៊ាន" ។*

សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រនៃកិច្ចប្រជុំកំពូលធុរកិច្ចលើកទី ២ រវាងអាស៊ាន និង សហភាពអឺរ៉ុប : www.ASEAN-EUBizSummit.com ឬទាក់ទងលោកស្រី **ពូន ប៉ុក** បម្រើការងារនៅប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា តាមរយៈទូរស័ព្ទលេខ (៨៥៥) (0) ២៣-២១៦៩៨៦ ឬអ៊ីម៉ែល pok.poun @eeas.europa.eu ។

No 100A – Preah Norodom Boulevard – Khan Daun Penh –12207 Phnom Penh – Cambodia
Tel: 855-23-216 996 / 211 102 / 220 611 / 220 612 – Fax: 855-23-216 997 – E-mail: Delegation-Cambodia@eeas.europa.eu
Website: http://eeas.europa.eu/delegations/cambodia